# ពី «ប» ទៅ «ស»

ជាធម្មជាតិ ភាសាតែងមានការប្រែប្រួលជានិច្ច។ ដោយសង្កេតជាធម្មតា ក៏យើងនឹងឃើញថាជនជាតិខ្មែររស់នៅតំបន់ផ្សេងៗគ្នា មានការប្រើប្រាស់ពាក្យពេជន៍ខុសប្លែកគ្នាមួយចំនួនដែរ។ ក្រៅពីពាក្យ ការបញ្ចេញសូរសំឡេង ក៏មានការខុសប្លែកគ្នាដោយអន្ទើផង។ អ្នកដែលរស់នៅតំបន់ផ្សេងៗក្នុងស្រុកខ្មែរ នឹងអាចកត់សម្គាល់ភ្លាមឃើញថាពាក្យដែលជាទូទៅគេបញ្ចេញសំឡេងអក្សរ «ស» អ្នកស្រុកមួយប៉ែកនៃខេត្តតាកែវ និងអ្នកខេត្តកំពត បញ្ចេញសំឡេងជាអក្សរ «ប» ឬ «ឆ» ទៅវិញ។ ក្នុងអត្ថបទនេះ យើងនឹងបង្ហាញអំពីពាក្យដែលមានបម្រែបម្រួលពីអក្សរ «ប» ទៅ «ឆ» និងទៅជា «ស» ដែលមានតាំងពីសម័យមុនអង្គរមក។

យើងគួររំលឹកបន្តិចដែលថា ភូមិភាគខាងត្បូងនៃប្រទេសកម្ពុជា ជាពិសេសខេត្តតាកែវ និងកំពត ជាតំបន់សំខាន់នាសម័យមុនអង្គរ។ នៅខេត្តកំពតមានប្រាសាទសំខាន់ៗនាសម័យមុនអង្គរដូចជាប្រាសាទភ្នំទទុង ប្រាសាទភ្នំខ្យង និងប្រាសាទភ្នំឈ្យោក។ ក្រៅពីនេះ យើងក៏ឃើញមានទួលប្រាសាទឬទួលអង្គសម័យមុនអង្គរជាច្រើន និងសិលាចារឹកសម័យមុនអង្គរមួយចំនួនដែលរកឃើញនៅខេត្តកំពតដូចជា៖ សិលាចារឹកគុហាហ្លួង K.៤៤ សិលាចារឹកប្រាសាទភ្នំឈ្យោក K.៤៦ សិលាចារឹកត្រពាំងធំ K.៤២៣ និងសិលាចារឹកទួលអង្គជីធ្មារ K.១៣៥២ ជាដើម។ ដូច្នេះហើយ ទើបយើងឃើញមានពាក្យខ្លះដែលអ្នកតាកែវ និងកំពតបញ្ចេញសំឡេង ទំនងជារក្សាសូរភាសាដែលបន្សល់មកតាំងពីសម័យមុនអង្គរ។

ពាក្យដែលយើងយកមកពិនិត្យដំបូងគេ គឺពាក្យដែលមានសំណេរជា «ច្មិង» និង «ច្មិង្ង»។ ពាក្យនេះ គេតែងប្រទះឃើញជាទូទៅក្នុងសិលាចារឹកសម័យមុនអង្គរ ដូចមានក្នុងសិលាចារឹកគុហាហ្លួង K.៤៤ ជាដើម។[១] ពាក្យនេះក្លាយមកជាពាក្យ «ស្មឹង» នាពេលបច្ចុប្បន្ន។ នៅសម័យអង្គរ ពាក្យនេះមានការប្រែប្រួលសំណេរជា «ឆ្មិង» និង «ឆ្មិង្ង»។[២]

---

[១] សូមអាន Jenner 2009A: 139។

[២] សូមអាន Jenner 2009B : 141។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

ដូច្នេះយើងសង្កេតឃើញថា នៅពេលមានការផ្លាស់ប្តូររាជធានីពីភាគខាងត្បូងប្រទេសកម្ពុជា មកតាំងទីនៅប៉ែកខាងជើងបឹងទន្លេសាបវិញ ភាសាក៏មានការប្រែប្រួលដែរ គឺទាំងការប្រែប្រួលសូរព្យញ្ជនៈ និងពាក្យពេជន៍ៗ នៅក្នុងសម័យកណ្តាល យើងពុំទាន់ជួបប្រទះសិលាចារឹកដែលមានពាក្យ «ស្ទឹង» នៅឡើយទេ។

ពាក្យមួយទៀតគឺពាក្យ «សម្លៀក» បច្ចុប្បន្ន ដែលមានសំណេរជា «ចន្ល្យាក៑ ចន្ល្យាក៑ ចន្ល្យាក្ក»[៣] នៅសម័យអង្គរ និង «ចន្លេក៑ ចំន្លេក៑»[៤] នៅសម័យមុនអង្គរ។

ដូច្នេះយើងឃើញថា ពាក្យដែលមានសូរព្យញ្ជនៈ «ស» ដែលអ្នកតាកែវ-កំពតបញ្ចេញសំឡេងជាព្យញ្ជនៈ «ច/ឆ» វិញនោះ គឺមានលក្ខណៈចាស់បុរាណ ដែលមានភស្តុតាងបញ្ជាក់តាមសិលាចារឹក តាំងពីសម័យមុនអង្គរមកម៉្លេះ។ ខាងក្រោមនេះ ជាសម្រង់ពាក្យដែលមានការប្រែប្រួលពី «ច» ទៅ «ឆ» និងទៅជា «ស» តាំងពីសម័យមុនអង្គរមក ដោយផ្អែកតាមទិន្នន័យសិលាចារឹក៖

| ពាក្យសម័យមុនអង្គរ | ពាក្យសម័យអង្គរ | ពាក្យសម័យបច្ចុប្បន្ន |
|---|---|---|
| ច្ទិង៑[៥] | ឆ្ទិង៑ | ស្ទឹង |
| ចន្លេក៑ | ចន្ល្យាក៑ | សម្លៀក |
| ចាយ៑ | ចាយ៑ | ចាយ & សាយ |
| ចោង៑ | ចោង៑ | ចង & សង់ |
| ចទិល៑ | --- | ស្ទឹល |
| *ច្ទក | --- | ស្ទាក់ |
| *ច្យ | ឆ្យ | ឆី & ស៊ី |
| *ច្លេក៑ | ឆ្ល្យាក៑ | ស្លៀក |

[៣] សូមអាន Jenner 2009B : 112។

[៤] សូមអាន Jenner 2009A: 119។

[៥] យើងជ្រើសរើសសំណេរតែមួយបែបគត់មកបង្ហាញ ដើម្បីកុំឱ្យមានភាពស្មុគស្មាញ ដ្បិតគោលបំណងសំខាន់ដែលបង្ហាញនេះ ដើម្បីឱ្យឃើញការប្រែប្រួលព្យញ្ជនៈ «ច» «ឆ» និង «ស» ប៉ុណ្ណោះ។ សំណេរដែលមិនបង្ហាញ គឺខុសគ្នាត្រង់ខាងចុងមានប្រើសញ្ញាវិរាម «៑» ឬប្រើតម្រួតព្យញ្ជនៈខាងចុងដូចគ្នាតែប៉ុណ្ណោះ។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

## បញ្ជីឯកសារយោង


Jenner, P. N.

2009A. *A dictionary of pre-Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.

2009B. *A dictionary of Angkorian Khmer*. Pacific linguistics, Research school of Pacific and Asian studies, the Australian national University.


## បញ្ជីរូបភាព



n. 847 / K. 688

*សិលាចារឹកប្រាសាទព្រៃប្រាសាទ ឆ្នាំ៧១៩គ.ស. (រូបថត៖* EFEO)

អត្ថបទដោយ៖ ហ៊ិន ឈុនតេង



សិលាចារឹកប្រាសាទឪឡោក ខេត្តសៀមរាប ស.វ.ទី៧-៨ (រូបថត៖ EFEO)




សិលាចារឹកកន្ទុយគោ ខេត្តស្ទឹងត្រែង ស.វ.ទី១០-១១មានពាក្យ «ធ្មិងសេនិ»
(រូបថតនិងសំណៅផ្តិត៖ ហេង ពិភាល់)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង